# ចូលស្ទឹង ជីកផ្លូវថ្មី

**(Critique of Adaptation)**




(Proactive Quote)

រីស្ទឹងតែងវែង ដំណើរឆ្ងាយ

នឹងចរត្រូវចាយ ពេលយូរក្រៃ

ផ្លូវមានតែមួយ ចួបគ្រោះក្ស័យ

គ្មានអ្នកសង្ស័យ ផ្លូវទីពីរ។

លុះចួបឧបសគ្គ ទៅលែងបាន

ទើបចេះក្លាហាន ឆ្លងវារី

មិនទាន់ទាល់ច្រក មិនផ្លាស់ទី

ត្រូវខ្យាល់ក្រវី ទើបភ្ញាក់ខ្លួន។




(Reactive Quote)

ដ្បិតជំនឿជាក់ មិនសូវមាន

សង្គមទិតៀន មិនសមសួន

បើមិនបត់តាម គ្រោះចួបចួន

ព្យុះមនុស្សមាំមួន ជាងជលសារ។

មិនទាន់ឡើងទូក ព្យុះមនុស្សមុន

ទឹកមាត់ជោរជន់ លិចមនសិការ

មនុស្សអន់បត់បែន យកសង្ខារ

មនុស្សខ្លាំងហានក្លា ហ៊ានប្រឈម។

ទោះគេរិះគន់ មិនគាំទ្រ

នៅសល់ជំហរ ទ្រកាយស្គម

ទោះគ្នាមានតិច សម្លេងមិនល្អម

អ្វីដែលផ្អែតព្រម សម្លេងទឹកចិត្ត។

គ្មានអ្នកគិតគូរ រកផ្លូវថ្មី

ទោះរងរីងរៃ ទាំងកាយចិត្ត

បើចួបគ្រោះស៊ូ បង់ជីវិត

ប្រសើរជាងគិត ហើយមិនធ្វើ។

បើសម្រេចនាំ ផ្លូវថ្មីឱយ

ទោះត្រូវខ្សោះខ្សោយ សល់ទង្វើ

មិនបានឆ្លងទៀត ក៏បានមើល៍

ឃើញក្ដីអើពើ អ្នកយល់ចិត្ត។

មិនប្រឆាំងតប អ្នករិះគន់

ជ័យជាទម្ងន់ ឱយមាត់បិត

អរគុណរាល់ការ ជាន់ឈ្លីពិត

ធ្វើឱយការគិត មុនការដើរ៕ល៚

មានគំនិតសរសេរ សៅរ៍, ២០/០៤/២០១៣

ប្រហែលផ្ដើម ២២:៣៥- សរសេរចប់ ២៣:១៦, ចន្ទ្រ, ២២/០៤/២០១៣

គំនិតចាស់ កំណាព្យថ្មី